ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ២៨២៧១ អពដ

L202307130032TD2763

ថ្ងៃ អង្គារ ១៤រោច ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការកែសម្រួលអត្រាអាករពិសេសលើផលិតផលភេសជ្ជៈគ្មានជាតិសុរាដែលផលិតក្នុងស្រុក

អនុលោមតាមច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបជូនដល់សហគ្រាសផលិតភេសជ្ជៈគ្មានជាតិសុរាទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ តទៅ អត្រាអាករពិសេសលើភេសជ្ជៈគ្មានជាតិសុរាដែលផលិត និងផ្គត់ផ្គង់ក្នុងស្រុក ត្រូវបានកែសម្រួល និងកំណត់ដូចខាងក្រោមៈ

១)១៥ (ដប់ប្រាំ)ភាគរយ លើភេសជ្ជៈប៉ូវកម្លាំងគ្រប់ប្រភេទ

២) ៥ (ប្រាំ) ភាគរយ លើភេសជ្ជៈគ្មានជាតិសុរាមួយចំនួន រួមមានៈ

- ភេសជ្ជៈបន្ថែមជាតិទឹកដោះគោដែលឆ្លងកាត់កំដៅអ៊ុលត្រាខ្ពស់
- ទឹកសណ្ដែក
- ភេសជ្ជៈមានមូលដ្ឋានពីទឹកដូង
- ភេសជ្ជៈមានមូលដ្ឋានពីកាហ្វេ ឬភេសជ្ជៈដែលបន្ថែមរសជាតិកាហ្វេ
- ភេសជ្ជៈគ្មានឧស្ម័នសម្រាប់ពិសាភ្លាមៗដោយពុំចាំបាច់ពង្រាវ

៣)១០(ដប់)ភាគរយ លើភេសជ្ជៈគ្មានជាតិសុរាក្រៅពីភេសជ្ជៈដែលបានកំណត់ក្នុងចំណុចទី១ និងទី២ ខាងលើ។

ដោយឡែក មូលដ្ឋានគិតអាករពិសេសត្រូវអនុវត្តស្របតាមខ្លឹមសារប្រកាសលេខ០១២ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ស្ដីពីការកែសម្រួលការកំណត់មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក ដូចដែលបាន និងកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយក បណ្ណាធិការ និងម្ចាស់សហគ្រាសផលិតផលិតផលភេសជ្ជៈគ្មានជាតិសុរាទាំងអស់ជ្រាប និងអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន ពន្ធដារ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គង់ វិបុល

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh